# ពលរដ្ឋរងផលប៉ះពាល់ពីគម្រោងអភិវឌ្ឍន៍ផ្លូវដែក ស្នើអាជ្ញាធរពន្លឿនការដោះស្រាយ ខណៈពួកគេបារម្ភពីការបណ្តេញចេញដោយបង្ខំ។



ពលរដ្ឋមួយក្រុមដែលរងផលប៉ះពាល់ពីគម្រោងអភិវឌ្ឍន៍ផ្លូវដែក នៅរាជធានីភ្នំពេញ ស្នើជាថ្មីទៀតទៅរដ្ឋបាលរាជធានីភ្នំពេញ ពន្លឿនការដោះស្រាយបញ្ហាដីធ្លីជូនពួកគេឱ្យបានឆាប់ ខណៈពួកគាត់បារម្ភពីការបណ្ដេញចេញដោយបង្ខំ និងមិនទទួលបានសំណងសមរម្យ ដោយសារអាជ្ញាធរនៅតែចង្អុលបង្ហាញឱ្យពួកគេទទួលយកដីនៅក្រុមហ៊ុន7NG ស្ថិតនៅខេត្តកណ្ដាល។

ប្រជាពលរដ្ឋរស់នៅភូមិ១៦ សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក លោក **គា ភារ៉ា** ដែលអះអាងថា រងផលប៉ះពាល់ពីគម្រោងអភិវឌ្ឍន៍ផ្លូវដែក នៅរាជធានីភ្នំពេញ បានឱ្យវិទ្យុអាស៊ីសេរីដឹងនៅថ្ងៃព្រហស្បតិ៍នេះថា កាលពីរសៀលថ្ងៃពុធម្សិលមិញ មន្ត្រីរដ្ឋបាលរាជធានីភ្នំពេញ បានណាត់ជួបប្រជាពលរដ្ឋដែលរងផលប៉ះពាល់ អាជ្ញាធរមូលដ្ឋាន និងមន្ត្រីមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីជជែកគ្នារកដំណោះស្រាយ។ លោកបន្តថា ក្រោយពីជួបជជែកគ្នា មន្ត្រីពាក់ព័ន្ធទាំងនោះនៅតែប្រាប់ពួកគាត់ឱ្យទទួលយកដីនៅតំបន់អភិវឌ្ឍន៍របស់ក្រុមហ៊ុន 7NG ស្ថិតនៅខេត្តកណ្ដាល និងតំបន់គោកខ្សាច់ ដែលមានចម្ងាយប្រមាណ ៥ ទៅ ៦គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ ដោយថា នៅតំបន់នោះកំពុងធ្វើការអភិវឌ្ឍ មានផ្លូវ ទឹក ភ្លើង ផ្សារ និងរោងចក្រ ក្បែរនោះថែមទៀតផង។

យ៉ាងណា លោកថា ពួកគាត់មិនព្រមទទួលយកដីនៅតំបន់អភិវឌ្ឍន៍របស់ក្រុមហ៊ុន 7NG នោះទេ ហើយពួកគេនៅតែទទូចទៅអាជ្ញាធរផ្ដល់ដីនៅក្បែរ **«វត្តទួលអស់លោក»** ឬដីក្នុងខណ្ឌទួលគោក ដែលស្ថិតនៅក្បែរទីប្រជុំជន ដើម្បីឱ្យពួកគាត់ងាយស្រួលរកប្រាក់ទ្រទ្រង់ជីវភាពគ្រួសារ និងងាយស្រួលកូនៗទៅសិក្សា ជាដើម។

លោកនិយាយថា៖ **«យើងសួរបងប្អូនប៉ុន្មានគ្រួសារហ្នឹង គាត់ចង់បានដីនៅក្បែរវត្តទួលអស់លោក ដោយសារដីនៅតំបន់នោះ វាមានការអភិវឌ្ឍខ្លាំងជាងតំបន់ផ្សេងៗ ពីព្រោះកន្លែងនោះ វាមានសាលារៀន មានមន្ទីរពេទ្យ ជិតហ្នឹងទាំងអស់! ហើយដូច**

នៅ 7NG តំបន់មិនទាន់អភិវឌ្ឍ មានប្រជាពលរដ្ឋជាច្រើនដែលគាត់បានចាកចេញទៅទីនោះ គាត់ថាអត់ទាន់មានទឹក មានភ្លើង ក៏អត់ទាន់មានការអភិវឌ្ឍទេ»។

ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ម្នាក់ទៀត អ្នកស្រី **មាស ស្រីភាព** រស់នៅភូមិ១៦ សង្កាត់ទឹកល្អក់១ បានឱ្យដឹងថា ពួកគេមិនជំទាស់នឹងគម្រោងអភិវឌ្ឍន៍ផ្លូវដែក នៅរាជធានីភ្នំពេញនោះទេ ប៉ុន្តែពួកគាត់ចង់បានសំណងសមរម្យ ដូចពលរដ្ឋដែលរងផលប៉ះពាល់ដូចគ្នា ពីព្រោះអ្នកដែលរងផលប៉ះពាល់នៅផ្លូវដែកនោះដូចគ្នា បែរជាអ្នកខ្លះទទួលបានដីនៅក្បែរ **«វត្តទួលអស់លោក»** ឬដីក្នុងខណ្ឌទួលគោក ដែលស្ថិតនៅក្បែរទីប្រជុំជន ខណៈពួកគេបែរជាអាជ្ញាធរផ្តល់ឱ្យទៅតំបន់អភិវឌ្ឍន៍របស់ក្រុមហ៊ុន 7NG ទៅវិញ។

ករណីនេះ អ្នកស្រីថា បើអាជ្ញាធរនៅតែមិនផ្តល់ដីនៅក្បែរ **«វត្តទួលអស់លោក»** ឬដីក្នុងខណ្ឌទួលគោកទេ នោះពួកគេនៅតែបន្តតវ៉ារហូតទទួលបានដំណោះស្រាយសមរម្យ។

អ្នកស្រីនិយាយដូច្នេះថា៖ «ពួកខ្ញុំប៉ះពាល់ផ្លូវដែកដូចគ្នា ឱ្យពួកខ្ញុំទៅនៅខាងគោកខ្សាច់ ខាងក្រុមហ៊ុន 7NG! អ៊ីចឹងវាខុសគ្នាឆ្ងាយមែនទែន ខ្ញុំអត់ទទួលយកទេ។ បើខ្ញុំសុំថាចង់បាននៅក្នុងខណ្ឌឫស្សីកែវ និងខណ្ឌទួលគោក។ បើអត់បាននៅក្នុងខណ្ឌហ្នឹង ខ្ញុំសុំឱ្យដូចខណ្ឌដែលគេចែកឱ្យអ្នកមុនមកក៏បានដែរ។ បើគេ[អាជ្ញាធរ]មិនព្រមយើងនឹងដាក់ញត្តិម្តងទៀត និងតវ៉ារហូតមានដំណោះស្រាយមួយសមរម្យដែលខ្ញុំទទួលយកបាន»។

វីអូឌី មិនអាចសុំការបញ្ជាក់ករណីនេះពីអ្នកនាំពាក្យរដ្ឋបាលរាជធានីភ្នំពេញលោក **ម៉េត មាសភក្តី** បានទេ នៅថ្ងៃនេះ ។

អ្នកសម្របសម្រួលគម្រោងធុរកិច្ច និងសិទ្ធិមនុស្ស នៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា លោក **វណ្ណ សុជាត** សង្កេតឃើញថា អាជ្ញាធរពាក់ព័ន្ធដែលដោះស្រាយបញ្ហាដីធ្លីជូនពលរដ្ឋដែលរងផលប៉ះពាល់ពីគម្រោងអភិវឌ្ឍន៍ផ្លូវដែកនេះ នៅមិនទាន់មានតម្លាភាពនៅឡើយ ដោយសារអ្នកខ្លះទទួលបានដីនៅក្នុងរាជធានីភ្នំពេញ និងខ្លះទៀតបែរជាអាជ្ញាធរបង្ខំឱ្យពួកគាត់ទៅយកនៅខេត្តកណ្ដាលទៅវិញ។ ករណីនេះ លោកជំរុញទៅអាជ្ញាធរពាក់ព័ន្ធ ត្រូវធ្វើការដោះស្រាយដីធ្លីជូនពលរដ្ឋដែលរងផលប៉ះពាល់ ទទួលបានសំណងដូចគ្នា ឬប្រហាក់ប្រហែលគ្នា ដើម្បីកុំឱ្យមានការរិះគន់ពីមជ្ឈដ្ឋានជាតិ និងអន្តរជាតិ។

លោកមានប្រសាសន៍ថា៖ «**យើងដឹងហើយថា** កន្លងមក មានការដកការអនុគ្រោះពន្ធពីសហភាពអឺរ៉ុប ពីសហរដ្ឋអាមេរិក មកដល់ពេលបច្ចុប្បន្ននេះ ដោយសារតែគេចង់ជំរុញរដ្ឋយើងឱ្យធ្វើការដោះស្រាយជូនប្រជាពលរដ្ឋ រួមទាំងប្រជាពលរដ្ឋដែលរងប៉ះពាល់ដោយសារដីធ្លីឱ្យបានសមរម្យ ឱ្យគោរពសិទ្ធិមនុស្ស ស្ដារឡើងវិញនូវលទ្ធិប្រជាធិបតេយ្យ គោរពសិទ្ធិមនុស្ស។ ប៉ុន្តែបើសិនជាយើងមិនបានអនុវត្ត ហើយនៅតែព្រងើយកន្តើយអនុសាសន៍របស់គេអ៊ីចឹង កិត្តិសព្ទរបស់រដ្ឋយើង នៅតែមានការវាយតម្លៃពីអន្តរជាតិ ថាប្រទេសយើងអន់ថយក្នុងការគោរពសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ»។

បើតាមការអះអាងរបស់តំណាងពលរដ្ឋ ពលរដ្ឋដែលរងផលប៉ះពាល់ពីគម្រោងផ្លូវដែកនេះមានប្រមាណ ៧០គ្រួសារ មកពីសហគមន៍ចំនួន៤ រួមមាន សហគមន៍អភិវឌ្ឍន៍ថ្មី សហគមន៍ភូមិ១៧ សហគមន៍ភូមិ២៣ ស្ថិតក្នុងខណ្ឌទួលគោក និងសហគមន៍ភូមិ២ ក្នុងខណ្ឌដូនពេញ។ ប៉ុន្តែរហូតមកដល់ពេលបច្ចុប្បន្ននេះ អាជ្ញាធរបានដោះស្រាយដីធ្លីជូនពលរដ្ឋដែលរងផលប៉ះពាល់ជាបណ្ដើរខ្លះហើយ ខណៈនៅសេសសល់មួយចំនួនទៀតកំពុងបន្តតវ៉ាទាមទារដីធ្លីមកដល់បច្ចុប្បន្ន៕